**៨-២-៣ បុណ្យចូលវស្សា**

*សម័យនោះព្រះពុទ្ធមានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ការនៅចាំវស្សា ព្រះមានព្រះភាគ មិនទាន់បានបញ្ញត្តដល់ ភិក្ខុទាំងឡាយនៅឡើយ ។ ភិក្ខុទាំងឡាយ ក៏ត្រាច់ទៅមកគ្រប់រដូវ ដូចជាវស្សានរដូវ ជាដើម ដែលជារដូវភ្លៀង។ មនុស្សទាំងឡាយក៏ពោលបន្តុះបង្អាប់ថាពួកសមណៈជាសក្យបុត្តិយ៍ មិនសមបើនឹង ដើរជាន់ស្មៅស្រស់ទាំងឡាយបៀតបៀននូវវត្ថុដែលមានជីវិតញុំាងសត្វតូចៗជាច្រើនឲ្យ ដល់នូវសេចក្តីវិនាសសោះ សូម្បីពួកបរិព្វាជក មានលទ្ធិដទៃ ជាអ្នកពោលនូវធម៌អាក្រក់ម្តេច គង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា សូម្បីពួកសត្វស្លាបនេះទៀតសោត ក៏គង់ធ្វើសំបុកលើចុងឈើទាំងឡាយ ហើយសម្ងំឈប់សម្រាកនៅចាំវស្សាដែរ។ ចំឡែកតែពួកសមណៈ ជាសក្យបុត្តិយ៍នេះ នៅតែដើរ ត្រាច់ទៅ ត្រាច់មក។ កាលមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ភិក្ខុទាំងឡាយ ក៏បានឮច្បាស់ហើយនាំសេចក្តីនេះទៅក្រាបទូលព្រះដ៏មានព្រះភាគ។ ក្នុងពេលនោះព្រះមានព្រះភាគក៏ទ្រង់ត្រាស់ហៅភិក្ខុ ទាំងឡាយមក ហើយមានបន្ទូលថា :*

*"តថាគត អនុញ្ញាត ឲ្យភិក្ខុចូលវស្សា (នៅចាំវស្សា)" ឯរយៈពេលចូលវស្សា ចំនួន ៣ ខែ គឺចាប់ពីថ្ងៃ ១ រោច ខែអាសាឍ ដល់ថ្ងៃពេញបូណ៌មី ខែអស្សុជ។*

*បើមានខែអាសាឍ ២ដង ត្រូវចាប់ថ្ងៃ ១រោច ខែអាសាឍក្រោយ(ទុតិយាសាឍ)។*

*ក្នុងពេលចូលវស្សា ភិក្ខុសង្ឃមិនអាចទៅស្នាក់នៅទីដទៃ (ក្រៅពីកន្លែងខ្លួន) បានទេ។ ភិក្ខុណាប្រព្រឹត្តកន្លង ភិក្ខុនោះឈ្មោះថាមានវស្សាដាច់ ត្រូវមានទោស(អាបត្តិ) ប៉ុន្តែបើមានកិច្ចសំខាន់ដូចជាមានគេនិមន្តទៅធ្វើបុណ្យជាដើមអាចនិមន្តទៅបានដោយវិធី*

*លើក សត្តាហករណីយ អស់រយៈពេលយ៉ាងយូរបំផុតត្រឹម ៧ ថ្ងៃ។ ភិក្ខុអ្នកនៅចាំវស្សាមិនដាច់ អស់រយៈពេល ៣ ខែ (ត្រៃមាស) ត្រូវបាន អានិសង្សចាំវស្សា និងមានសិទ្ធិទទួលកឋិនបានទៀត ។ តាមធម្មតា បុណ្យចូលវស្សា ពុទ្ធបរិស័ទតែងតែយកវស្សិកសាដកចីវរ (សំពត់ស្រង់ទឹកភ្លៀង) ទៅប្រគេនព្រះសង្ឃ ព្រោះព្រះពុទ្ធអង្គ បានអនុញ្ញាតឲ្យភិក្ខុស្វែងរកទុកប្រើប្រាស់តាំងពីមុនពេលចូលវស្សា ១ ខែម្ល៉េះ ។ លើសពីនេះទៀតនៅវត្តពីបូរាណកាល មានបវារណា បើកឱកាស ជួយសម្រួលដល់ភិក្ខុសង្ឃដែលមានការខ្វះខាតនូវបច្ច័យ៤។*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*